Disability Rights California
ប្រព័ន្ធការការពារ និងការតស៊ូមតិរបស់រដ្ឋកាលីហ្វ័រនីញ៉ា
ទូរស័ព្ទហៅមិនអស់ប្រាក់ (800) 776-5746

# បញ្ញត្តិបេឡាសន្តិសុខសង្គមសម្រាប់ចាត់ជាប្រាក់ចំណូលពីឪពុកម្ដាយ ចំពោះក្មេងពិការ ដើម្បីកំណត់ថាតើកុមារពិការមានសិទ្ធិទទួលប្រាក់ចំណូលសន្តិសុខបង្គ្រប់ ដែរឬទេ ហើយបើគេមានសិទ្ធិ តើអាចទទួលបានប៉ុន្មាន

*ខែកក្កដា ឆ្នាំ២០១៦ អត្ថបទបោះពុម្ពផ្សាយលេខ ៖* **5017.06 - Cambodian**

ជាទូទៅ ប្រាក់ចំណូល និងធនធានរបស់ឪពុកម្ដាយត្រូវបាន “ចាត់ជាប្រាក់ចំណូល” ឬសន្មតជាប្រាក់ចំណូល ចំពោះក្មេងដែលទទួលប្រាក់ចំណូលសន្តិសុខបង្គ្រប់ (SSI, Supplemental Security Income) ។ ត្រង់នេះ មានន័យថា ផ្នែកនៃប្រាក់ចំណូលរបស់ឪពុកម្ដាយ គឺជាធនធានដែលត្រូវរាប់ជាប្រាក់ចំណូលចំពោះកុមារ ក្នុងការកំណត់ថាតើកុមារនោះមានសិទ្ធិទទួលបានប្រាក់ចំណូលសន្តិសុខបង្គ្រប់ដែរឬទេ ។ ឯកសារបោះពុម្ពផ្សាយនេះ ពន្យល់អំពី
បទបញ្ញត្តិនៃការចាត់ជាប្រាក់ចំណូលចំពោះកុមារពិការ ជាពិសេសវិធីកំណត់ថាតើប្រាក់ចំណូលចំនួនប៉ុន្មានដែលត្រូវចាត់ថាជាប្រាក់ពីឪពុកម្ដាយមកលើកូនដែលជាក្មេងពិការ និងវិធីកំណត់ថាតើកុមារពិការមានលក្ខណៈសម្បត្តិ
ទទួលបានប្រាក់ចំណូលសន្តិសុខបង្គ្រប់ដែរឬទេ ។

នៅមុនពេលឈានចូលក្នុងទម្រង់ការពិតប្រាកដ សម្រាប់ការគណនាចំនួនប៉ុន្មាននៃប្រាក់ចំណូលរបស់ឪពុកម្ដាយដែលត្រូវចាត់ជាប្រាក់ចំណូលរបស់កុមារ និងថាតើកុមារអាចទទួលបានប្រាក់ចំណូលសន្តិសុខបង្គ្រប់ចំនួនប៉ុន្មាន អ្នកត្រូវយល់ដឹងអំពី “គណនេយ្យប្រតិសកម្មប្រចាំខែ” (“Retrospective Monthly Accounting”)

របស់ប្រព័ន្ធប្រាក់ចំណូលសន្តិសុខបង្គ្រប់ និងកាតព្វកិច្ចរាយការណ៍របស់អ្នក ។ បេឡាសន្តិសុខសង្គម រាប់ចំពោះតែប្រាក់ចំណូល និងធនធានរបស់ឪពុកម្តាយដែលកុមារទទួលបានប្រាក់ចំណូលសន្តិសុខបង្គ្រប់ រស់នៅជាមួយតែប៉ុណ្ណោះ ។ ឡាសន្តិសុខសង្គម(Social Security)មិនរាប់ប្រាក់ចំណូល ឬធនធានរបស់ឪពុកម្តាយដែលកុមារទទួលបានប្រាក់ចំណូលសន្តិសុខបង្គ្រប់មិនបានរស់នៅជាមួយឡើយ ។ ប្រាក់ចំណូលរបស់ឪពុក/ម្តាយចុង ដែលកុមារទទួលបានប្រាក់ចំណូលសន្តិសុខបង្គ្រប់រស់នៅជាមួយគឺត្រូវរាប់បញ្ចូល[1] ។

## គណនេយ្យប្រតិសកម្មប្រចាំខែ

បេឡាសន្តិសុខសង្គមប្រើគណនេយ្យប្រតិសកម្មប្រចាំខែក្នុងអំឡុងពេលដែលកូនអ្នកមានសិទ្ធិទទួលបានប្រាក់ចំណូលសន្តិសុខបង្គ្រប់ ។ ក្រម 20 នៃបទបញ្ញត្តិសហព័ន្ធ (C.F.R., Code of Federal Regulations) វគ្គទី 416.420 ។ គឺមានន័យថា ប្រាក់ចំណូលដែលអ្នកបានទទួលក្នុងមួយខែ កំណត់នូវចំនួនប្រាក់ជំនួយពីប្រាក់ចំណូលសន្តិសុខបង្គ្រប់សម្រាប់ពីរខែក្រោយ ។ ឧទាហរណ៍ ប្រាក់ចំណូលដែលអ្នកបានទទួលក្នុងខែមករា មានការប៉ះពាល់ចំពោះសែកប្រាក់ជំនួយពីចំណូលសន្តិសុខបង្គ្រប់ក្នុងខែមីនា ។ ទោះជាយ៉ាងណាក៏ដោយ បើប្រាក់ចំណូលរបស់អ្នកមានចំនួនច្រើនពេកក្នុងខែណាមួយដែលធ្វើឲ្យកូនរបស់អ្នកមិនមានសិទ្ធិទទួលបានជំនួយនៃចំណូលសន្តិសុខបង្គ្រប់ នោះចំណូលសន្តិសុខបង្គ្រប់ត្រូវព្យួរសម្រាប់ខែនោះ ។ ដូច្នោះ បើប្រាក់ចំណូលក្នុងខែមករា របស់អ្នកមានចំនួនច្រើនពេក ដែលធ្វើឲ្យកូនរបស់អ្នកមិនមានសិទ្ធិទទួលបានជំនួយចំណូលសន្តិសុខបង្គ្រប់ នោះចំណូលសន្តិសុខបង្គ្រប់សង្គមរបស់កូនអ្នកក្នុងខែមករា ត្រូវព្យួរទុកសិន ។ កូនរបស់អ្នកមានសិទ្ធិទទួលបានជំនួយឡើងវិញជាស្វ័យប្រវត្តិ ដោយមិនបាច់មានការដាក់ពាក្យសុំថ្មី បើប្រាក់ចំណូលរបស់អ្នក មានចំនួនតិចល្មមឲ្យកូនអ្នកមានលក្ខណៈសម្បត្តិអាចទទួលបានចំណូលសន្តិសុខបង្គ្រប់ក្នុងខែណាមួយនៃខែ[2] ចំនួន ១១ ជាបន្តបន្ទាប់ ។ ក្រម 20 នៃ បទបញ្ញត្តិសហព័ន្ធ វគ្គទី 416.1323(b) ។ បើអ្នកមានប្រាក់ចំណូលខ្ពស់ចំនួន ១២ខែ ដោយក្នុងពេលនេះប្រាក់ចំណូលរបស់អ្នកមិនចុះថយមកក្នុងបរិមាណទាបសមរម្យ ដើម្បីឲ្យកូនអ្នកអាចមានសិទ្ធិទទួលបានចំណូលសន្តិសុខបង្គ្រប់ទេនោះ ការព្យួរជំនួយរបស់កូនអ្នកនឹងត្រូវប្តូរទៅជាការបញ្ចប់ភាពមានសិទ្ធិទទួលជំនួយតែម្តង ។ ក្រម 20 នៃបទបញ្ញត្តិសហព័ន្ធ វគ្គទី 416.1335 ។ នៅពេលដែលកូនរបស់អ្នកត្រូវបញ្ចប់សិទ្ធិទទួលជំនួយ ហើយ អ្នកត្រូវដាក់ពាក្យសុំសារជាថ្មី ទើបកូនអ្នកមានសិទ្ធិទទួលចំណូលសន្តិសុខបង្គ្រប់ម្តងទៀត ។

## កាតព្វកិច្ចរាយការណ៍អំពីការផ្លាស់ប្តូរប្រាក់ចំណូលរបស់ឪពុកម្តាយ

ដើម្បីឲ្យ "ប្រតិសកម្មគណនេយ្យប្រចាំខែ" មានដំណើរការទៅបាន បេឡាសន្តិសុខសង្គម មានបទបញ្ញត្តិមួយដែលសរសេរថា អ្នកត្រូវ ប្រាប់បេឡាសន្តិសុខសង្គមឲ្យបានដឹងត្រឹមថ្ងៃទី១០ នៃខែ *បន្ទាប់ពី* ខែដែលប្រាក់ចំណូល របស់អ្នកបានផ្លាស់ប្តូរ ។ ក្រម 20 នៃបទបញ្ញត្តិសហព័ន្ធ វគ្គទី 416.708(c) 416.714[3] ។ បើប្រាក់ចំណូលក្នុងខែមករារបស់អ្នកមានចំនួនច្រើន ឬតិចជាងប្រាក់ចំណូល របស់អ្នកក្នុងខែធ្នូ អ្នកត្រូវរាយការណ៍អំពីការផ្លាស់ប្តូរនេះ ឲ្យបេឡាសន្តិសុខសង្គមបានដឹងត្រឹមថ្ងៃទី ១០ នៃខែកុម្ភៈ – *តែជារឿងល្អ បើអ្នក រាយការណ៍បានត្រឹមថ្ងៃទី ៥ កុម្ភៈ*។ អ្នកមិនចាំបាច់រាយការណ៍អ្វីឡើយ បើប្រាក់ចំណូលរបស់អ្នកក្នុងខែមករា មានចំនួនដូចគ្នានឹងប្រាក់ចំណូលក្នុងខែធ្នូ ។ នៅពេលដែលបេឡាសន្តិសុខសង្គមទទួលបានរបាយការណ៍អំពីការប្រែប្រួលប្រាក់ចំណូល របស់អ្នកសម្រាប់ខែមករា បេឡាសន្តិសុខសង្គម ត្រូវបញ្ចូលព័ត៌មានការ ផ្លាស់ប្តូរនេះទៅក្នុងម៉ាស៊ីនកុំព្យូទ័រ ដើម្បីកែសម្រួលដោយតម្លើង ឬបន្ថយជំនួយប្រាក់ចំណូលសន្តិសុខបង្គ្រប់របស់កូនអ្នកសម្រាប់ខែមីនា ឲ្យស្របជាមួយ នឹងការផ្លាស់ប្តូរចំណូលរបស់អ្នកក្នុងខែមករា ។

យើងបានដាក់បញ្ចូលបែបបទរបាយការណ៍គំរូអំពីការប្រែប្រួលប្រាក់ចំណូល ដើម្បី ជួយអ្នកក្នុងការរាយការណ៍អំពីការប្រែប្រួលប្រាក់ចំណូល ។ យើងខ្ញុំសូមណែនាំឲ្យអ្នក បំពេញរបាយការណ៍នេះមួយផ្នែកសិន ដោយការសរសេរអាសយដ្ឋានរបស់ ការិយាល័យសន្តិសុខសង្គមរបស់អ្នក ព្រមទាំងព័ត៌មានទាំងអស់បន្ទាប់ពីពាក្យ "កម្មវត្ថុ" ។ រួចហើយសូមថតចម្លងឲ្យបានច្រើនចំពោះបែបបទដែលបានបំពេញព័ត៌មានខ្លះៗ រួចហើយ ។

ក្នុងខែនីមួយៗដែលប្រាក់ចំណូលរបស់អ្នកប្រែប្រួល សូមសរសេរកាលបរិច្ឆេទចូល នៅពេលអ្នកចុះហត្ថលេខាចំពោះខែដែលអ្នករាយការណ៍ និងព័ត៌មានអំពីប្រាក់ចំណូល នៅខាងក្រោមនៃបែបបទនោះ ។ រួចហើយចុះហត្ថលេខា ។ គឺត្រូវការតែឪពុក ឬម្តាយម្នាក់ប៉ុណ្ណោះក្នុងការចុះហត្ថលេខាលើបែបបទនេះ ។ អ្នកអាចថតចម្លង ឬបំពេញព័ត៌មានក្នុងបែបបទទីពីរ ដើម្បីជាសំណៅសម្រាប់អ្នករក្សាទុក ។ ត្រូវភ្ជាប់មកជាមួយនឹងបែបបទរបាយការណ៍ដែលអ្នកត្រូវផ្ញើមកកាន់បេឡាសន្តិសុខស ង្គម នូវសន្លឹក ឬសែកប្រាក់ចំណូល ។ ត្រូវភ្ជាប់សំណៅដើមនៃសន្លឹក ឬសែកប្រាក់ចំណូល ទៅនឹងសំណៅរបាយការណ៍ដែលអ្នករក្សាទុកជាឯកសារ ។ ហាមផ្ញើមកឲ្យបេឡាសន្តិសុខសង្គមនូវសន្លឹកទទួលប្រាក់ចំណូលច្បាប់ដើម

គឺសូមផ្ញើមកតែសំណៅថតចម្លង[4]សំណៅថតចម្លងបានហើយ ។
របស់ដែលផ្ញើមកឲ្យបេឡាសន្តិសុខសង្គម តាមប្រៃសនីរមែងបាត់បង់ ។
សូមរក្សាទុកច្បាប់ដើមនៃសន្លឹក ឬសែកប្រាក់ចំណូលជាមួយនឹងសំណៅរបាយការណ៍ដែល
អ្នកទុកជាឯកសារ ដើម្បីឲ្យបេឡាសន្តិសុខសង្គមអាចពិនិត្យឡើងវិញ
នូវសំណៅច្បាប់ដើម នៅពេលយើងខ្ញុំពិនិត្យសំណុំរឿងរបស់អ្នកប្រចាំឆ្នាំ ។
នៅក្នុងសំណៅរបាយការណ៍ផ្លាស់ប្តូរប្រាក់ចំណូលដែលអ្នករក្សាទុក
សូមសរសេរចូលនូវកាលបរិច្ឆេទដែលអ្នកបានផ្ញើសំបុត្រតាមប្រអប់សំបុត្រ[5] ។
សូមរក្សាសំណៅមួយច្បាប់ទុកនូវអ្វីៗទាំងអស់ដែលអ្នកផ្ញើមកឲ្យបេឡាសន្តិសុខសង្គម ។

លើសពីនេះ ត្រូវរក្សាកំណត់ត្រាទុករាល់ពេលដែលអ្នកនិយាយជាមួយនឹង
បេឡាសន្តិសុខសង្គម ។ សូមសរសេរចូលកាលបរិច្ឆេទដែលអ្នកបាននិយាយ
និយាយជាមួយនរណា និងអ្វីដែលអ្នកបាននិយាយ ។
យើងខ្ញុំសូមណែនាំឲ្យអ្នករក្សាទុកនូវអ្វីដែលអ្នកបានទទួលពីបេឡាសន្តិសុខសង្គម
ហើយថតទុកជាសំណៅអ្វីដែលអ្នកបានផ្ញើមកឲ្យយើងខ្ញុំដោយចោះជាបិរន្ធ ។
យករបស់ទាំងនេះទុកក្នុងសៀវភៅសរសេរ ឬក្នុងសឺមី ។

## ធនធាន និងប្រាក់ចំណូលដែលមិនបានចាត់ចូលជាប្រាក់ចំណូលរបស់កុមារ

បេឡាសន្តិសុខសង្គម មិនរាប់បញ្ចូលអ្វីៗខាងក្រោមថាជាប្រាក់ចំណូលរបស់កុមារ សម្រាប់
គោលបំណងកំណត់អំពីសិទ្ធិទទួលជំនួយចំណូលសន្តិសុខបង្គ្រប់របស់កូនអ្នកទេ ៖

- ប្រាក់បំណាច់ ឬប្រាក់ចូលនិវត្តន៍របស់ឪពុកម្តាយ (ដូចជា គណនីចូលនិវត្តន៍របស់បុគ្គល, KEOGH ឬប្រាក់ពន្យារពេលបង់ពន្ធប្រចាំឆ្នាំ) បើទោះបីជាប្រាក់ទាំងនោះ ត្រូវប្រគល់ឲ្យអ្នកវិញក៏ដោយ ។ ក្រម 20 នៃបញ្ញត្តិសហគមន៍ វគ្គទី 416.1202(b) ។
- ធនធានដែលត្រូវបានប្រើសម្រាប់ការជ្រោមជ្រែងផ្ទាល់ខ្លួន ដូចជា បញ្ជីសារពើភ័ណ្ឌនៃមុខរបរខ្នាតតូច និងគណនី ឧបករណ៍ប្រតិបត្តិការធនាគារ សម្ភារៈ ឬយានយន្តទីពីរដែលត្រូវប្រើនៅពេលធ្វើការ ឬដែលចាំបាច់ត្រូវប្រើ ដើម្បីចេញទៅធ្វើការ ។ ក្រម 42 សហរដ្ឋអាមេ រិក (U.S.C., United States Code) វគ្គទី 1382b(a)(3) ។

បេឡាសន្តិសុខសង្គមមិនរាប់បញ្ចូលអ្វីៗខាងក្រោមថាជាប្រាក់ចំណូល
សម្រាប់គោលបំណងកំណត់អំពីសិទ្ធិទទួលចំណូលសន្តិសុខបង្គ្រប់របស់កូនអ្នកទេ ៖

- ប្រាក់ចំណូលដែលឪពុកម្តាយទទួលបានក្នុងការ ផ្តល់សេវាកម្មជ្រោមជ្រែងដល់អ្នកជម្ងឺនៅតាមផ្ទះ (IHSS, In-Home Supportive Services) ដល់កុមារពិការ ។ ប្រាក់ចំណូលពីការងារផ្តល់សេវាកម្មជ្រោមជ្រែងដល់អ្នកជម្ងឺនៅតាមផ្ទះ គឺជាប្រាក់ចំណូលដែលបេឡាសន្តិសុខសង្គមលើកលែង ។ ក្រម 20 នៃបទបញ្ញត្តិសហព័ន្ធ វគ្គទី 416.1161(a)(16) ។
- តាមរយៈអំណាចជ្រើសរើសទីមួយរបស់សហគមន៍ (CFCO, Community First Choice Option) កិច្ចការផ្តល់សេវាកម្មជ្រោមជ្រែងដល់អ្នកជម្ងឺនៅតាមផ្ទះដែលឪពុកម្តាយផ្តល់ឲ្យកុមារមានការធានារ៉ាប់រងពី Medi-Cal ហើយប្រាក់ចំណូលដែលឪពុកម្តាយទទួលបាននេះ គឺជាប្រាក់ចំណូលដែលលើកលែងដោយ Medi-Cal ។ លើសពីនេះ ប្រាក់ចំណូល និងធនធានដែលត្រូវបានរាប់សម្រាប់ គោលបំណងនៃការកំណត់សិទ្ធិទទួល ជំនួយហិរញ្ញវត្ថុពីប្រាក់ចំណូលសន្តិសុខបង្គ្រប់ និងបរិមាណ ជំនួយប្រាក់ចំណូលសន្តិសុខបង្គ្រប់របស់កុមារ មិនអាចរាប់បញ្ចូលសារជាថ្មី ដើម្បីកំណត់សិទ្ធិទទួលជំនួយ Medi-Cal របស់សមាជិកដទៃក្នុងគ្រួសារ[6] បានឡើយ ។

សម្រាប់ព័ត៌មានបន្ថែមអំពីសេវាកម្មជ្រោមជ្រែងដល់អ្នកជម្ងឺនៅតាមផ្ទះ សូមអាន សំណុំឯកសាររបស់យើងខ្ញុំ ស្តីអំពីសវនាការយុត្តិធម៌ IHSS និងការវាយតម្លៃខ្លួនឯង (IHSS Fair Hearing and Self-Assessment) ៖ http://www.disabilityrightsca.org/pubs/501301.htm

## ការគណនាចំនួនចាត់ជាប្រាក់ចំណូលរបស់កុមារ

បញ្ញត្តិចំពោះការចាត់ប្រាក់ចំណូលរបស់ឪពុកម្តាយ ជាប្រាក់ចំណូលរបស់កូន មានសរសេរនៅក្នុង ក្រម 20 នៃបទបញ្ញត្តិសហព័ន្ធ វគ្គទី 416.1160, 416.1161 និងវគ្គទី 416.1165 ។ "ប្រាក់ចំណូលពីមុខរបរ" គឺរួមបញ្ចូលនូវប្រាក់ពលកម្ម និងប្រាក់ខែ ឬប្រាក់ចំណូលពីមុខរបរផ្ទាល់ខ្លួន[7] ។ អ្វីៗក្រៅពីនេះ ត្រូវចាត់ជា "ប្រាក់ចំណូលក្រៅមុខរបរ" ៖ អំណោយ អត្ថប្រយោជន៍ពីភាពគ្មានការងារធ្វើ អត្ថប្រយោជន៍ពិការភាពរបស់រដ្ឋ និងអត្ថប្រយោជន៍បេឡាសន្តិសុខសង្គម ទាំងអស់នេះគឺសុទ្ធតែជាឧទាហរណ៍នៃប្រាក់ចំណូលក្រៅមុខរបរ ។ អ្នកត្រូវដាក់បញ្ចូលគ្នានូវប្រាក់ចំណូលក្រៅមុខរបររួមគ្នារបស់ឪពុកម្តាយ ។ អ្នកក៏ត្រូវ ដាក់បញ្ចូលគ្នានូវប្រាក់ចំណូលពីមុខរបររបស់ឪពុកម្តាយផងដែរ ។ ចំពោះប្រាក់ចំណូល

ពីមុខរបរ អ្នកត្រូវរាប់ចំនួនប្រាក់ចំណូលដុល គឺមិនមែនចំនួនដែលនៅសល់នោះទេ ។ ប្រាក់ចំណូលដុល គឺជាចំនួនប្រាក់ចំណូលសរុបដែលអ្នកទទួលបានមុនកាត់កង[៨]។

បេឡាសន្តិសុខសង្គម ចាប់ផ្តើមគណនា ដោយការកាត់កងប្រាក់ដែលលៃសម្រាប់កូនមិនពិការនៅក្នុងគ្រួសារ ចេញពីកូនដែលទទួលបានប្រាក់ចំណូលសន្តិសុខបង្គ្រប់ ឬកុមារពិការ ។ ដំបូងអ្នកត្រូវកាត់កងចេញពីប្រាក់ចំណូលមិនបានពីមុខរបរ រួចហើយ គិតអំពីប្រាក់ដែលមិនបានប្រើ ដែលត្រូវកាត់ចេញពីប្រាក់ចំណូលបានពីមុខរបរ (សូមមើលឧទាហរណ៍) ។ “កុមារ” សម្រាប់គោលបំណងនៃការកាត់កង គឺរួមបញ្ចូលកុមារដែលមានអាយុក្រោម២១ឆ្នាំ ដែលរស់នៅក្នុងផ្ទះតែមួយ  និងកុមារអាយុ២១ឆ្នាំ ដែលជាសិស្សពេញម៉ោង ក្រោមបទដ្ឋានក្នុង ក្រម 20 នៃបទបញ្ញត្តិសហព័ន្ធ វគ្គទី 416.1861 ។  ការលៃប្រាក់សម្រាប់កូនមិនពិការម្នាក់ៗ គឺជាភាពខុសគ្នារវាង អត្រាអត្ថប្រយោជន៍សហព័ន្ធរបស់បុគ្គល (FBR, Federal Benefit Rate) និង អត្រាអត្ថប្រយោជន៍សហព័ន្ធរបស់ប្តីប្រពន្ធ ។ (អត្រាអត្ថប្រយោជន៍សហព័ន្ធ គឺជាផ្នែកនៃសែកប្រាក់ចំណូលសន្តិសុខបង្គ្រប់ ដែលចេញពីរដ្ឋាភិបាលសហព័ន្ធ ចំណែកប្រាក់ដែលនៅសល់ក្នុងសែកប្រាក់ចំណូលសន្តិសុខបង្គ្រប់ គឺជាប្រាក់[៩]  របស់រដ្ឋ ។ ប្រាក់ចំណូលរបស់កុមារដែលមិនមានសិទ្ធិទទួលបានបេឡាសន្តិសុខបង្គ្រប់ នឹងកាត់បន្ថយនៃការលៃប្រាក់ចំណែកនេះ ។  ទោះជាយ៉ាងណាក៏ដោយ បើកុមារដែលមិនមានសិទ្ធិទទួលបានប្រាក់ចំណូលសន្តិសុខបង្គ្រប់ គឺជាសិស្សពេញម៉ោង ប្រាក់ចំណូលដែលរកបាន នឹងត្រូវលើកលែង ទៅតាមកម្រិតដែលត្រូវលើកលែងចំពោះកុមារដែលទទួលបានប្រាក់ចំណូលសន្តិសុខបង្គ្រប់ ឬយុវវ័យដែលមានអាយុក្រោម ២២ ឆ្នាំ ។  ក្រម 20 នៃបទបញ្ញត្តិសហព័ន្ធ វគ្គទី 416.1112(c)(3),416.1160(d), 416.1161(c), 416.1163(b), 416.1165, 416.1861 ។

បន្ទាប់ពីការកាត់កងរួចរាល់ សម្រាប់កូនមិនពិការនៅក្នុងគ្រួសារ អ្នកត្រូវកាត់ប្រាក់ចំនួន $២0.00 ចំពោះប្រាក់ចំណូលណាមួយ ដែលមិនសំដៅលើប្រាក់ចំណូលក្រៅមុខរបរ (បើមាន ឬបើមាននៅសល់) រួចហើយកាត់កងចេញពីប្រាក់ចំណូលពីការងារ ក្រៅពីការកាត់កងដែលមិនបានប្រើសម្រាប់ប្រាក់ចំណូលក្រៅមុខរបរ ។ បន្ទាប់មកគឺជាការកាត់កងពិសេសចំពោះប្រាក់ចំណូលពីមុខរបរ – ដំបូងត្រូវកាត់ចំនួន $៦៥.00 បន្ទាប់មកគឺកាត់ចំនួន ៥0% នៃសមតុល្យ ។  បន្ទាប់មក អ្នកត្រូវបូកបន្ថែមចំនួនប្រាក់ចំណូលក្រៅមុខរបរ និងចំនួនប្រាក់ចំណូលពីមុខរបរដែលនៅសល់ ។  ចេញពីចំនួនសរុបនេះ អ្នកត្រូវកាត់

កងចំពោះអត្រាអត្ថប្រយោជន៍សហព័ន្ធសម្រាប់បុគ្គល (បើអ្នកជាឪពុក ឬម្ដាយទោល) ឬអត្រាអត្ថប្រយោជន៍សហព័ន្ធសម្រាប់ប្ដី/ប្រពន្ធ (បើឪពុកម្ដាយទាំងពីរ ឬឪពុក/ម្ដាយ និងឪពុក/ម្ដាយចុងរស់នៅក្នុងផ្ទះជាមួយគ្នា) ។ សមតុល្យត្រូវចាត់ចូលជាប្រាក់ចំណូលរបស់កូនដែលជាក្មេងពិការ គឺជាប្រាក់ចំណូលក្រៅមុខរបររបស់កុមារ ។ បើក្នុងគ្រួសារអ្នកមានក្មេងពិការច្រើនជាងមួយនាក់ ចំនួនប្រាក់ដែលត្រូវចាត់ជាប្រាក់ចំណូល គឺត្រូវបែងចែកក្នុងចំណោមពួកគេទាំងអស់ ។

ប្រាក់ឧបត្ថម្ភពីចំណូលសន្តិសុខបង្គ្រប់របស់កុមារ ត្រូវបានកំណត់តាមរបៀបដូចគ្នាទៅនឹងបុគ្គលទូទៅដែលទទួលបានចំណូលសន្តិសុខបង្គ្រប់ ដោយមានការលើកលែងចំនួនពីរ ។ ដំបូង គឺយើងរាប់យកតែពីរភាគបីនៃប្រាក់ឧបត្ថម្ភណាមួយចំពោះក្មេង ។ ក្រម 20 នៃបទបញ្ញត្តិសហព័ន្ធ វគ្គទី 416.1124(c)(11) ។ ទីពីរ បើក្មេងជាសិស្ស ហើយមានអាយុក្រោម ២២ ឆ្នាំក្នុងឆ្នាំ ២០១៦ បេឡាសន្តិសុខសង្គមមិនរាប់បញ្ចូលប្រាក់ចំនួន $១,៧៨0.00 ដំបូងនៃចំណូលពីការងារ ក្នុងខែនីមួយៗ រហូតដល់ទៅចំនួនជាអតិបរមា $៧,១៨0.00 ប្រចាំឆ្នាំ ។ ក្រម ២0 នៃបទបញ្ញត្តិសហព័ន្ធ វគ្គទី 416.1112(c)(3)[10] ។ នេះជាអ្វីដែលបន្ថែមពីលើការកាត់កងដែលអនុវត្តបានជាទូទៅចំពោះប្រាក់ចំណូលពីការងារ ។

## ឧទាហរណ៍នៃការប្រើបទបញ្ញត្តិការចាត់ប្រាក់ចំណូលជាប្រាក់ចំណូលរបស់ក្មេង

អ្វីដែលបានរួមបញ្ចូលក្នុងអនុស្សារណៈនេះ គឺជាតារាងទទេ (សូមមើលខាងក្រោម) ។ អ្នកអាចត្រូវថតចម្លងទុកឲ្យបានច្រើនច្បាប់នៃតារាងនេះ ដើម្បីធ្វើការគណនាចំនួននៃចំណូលសន្តិសុខបង្គ្រប់របស់កូនអ្នក ។ លើសពីនេះ យើងខ្ញុំបានដាក់ភ្ជាប់តារាងចំនួនពីរ ដែលត្រូវបានបំពេញដោយប្រើឧទាហរណ៍ “ក” និង “ខ” ។ ការគណនា គឺផ្អែកលើចំនួនអត្ថប្រយោជន៍ឆ្នាំ ២០១៦ ។ តួលេខ និងអក្សរខាងក្រោម គឺឆ្លើយគ្នាចំពោះតួលេខ និងអក្សរ នៅក្នុងតារាងការចាត់ប្រាក់ចំណូល ថាជាប្រាក់ចំណូលរបស់កុមារ ។

ការចាត់ប្រាក់ចំណូលសម្រាប់កុមារពីឪពុកម្ដាយដែលមានកូនទទួលបាន ចំណូលសន្តិសុខបង្គ្រប់

| | | |
|---|---|---|
| អត្រាអត្ថប្រយោជន៍សហព័ន្ធសម្រាប់ បុគ្គលក្នុងខែមករា ឆ្នាំ២០១៦ គឺ $៧៣៣.00 | អត្រាអត្ថប្រយោជន៍ សហព័ន្ធសម្រាប់បុគ្គល ក្នុងខែមករា ឆ្នាំ២០១៤ គឺ $៧២១.00 | អត្រាអត្ថប្រយោជន៍សហព័ន្ធសម្រាប់បុគ្គលក្នុងខែមករា ឆ្នាំ២០១៥ គឺ $៧៣៣.00 |
| អត្រា អត្ថប្រយោជន៍សហព័ន្ធសម្រាប់ប្ដីប្រពន្ធ ក្នុងខែមករា ឆ្នាំ២០១៦ គឺ $១,១00.00 | អត្រា អត្ថប្រយោជន៍សហព័ន្ធសម្រាប់ប្ដីប្រពន្ធ ក្នុងខែមករា ឆ្នាំ២០១៤ គឺ $១,0៨២.00 | អត្រា អត្ថប្រយោជន៍សហព័ន្ធ សម្រាប់ប្ដីប្រពន្ធ ក្នុងខែមករា ឆ្នាំ២០១៥ គឺ $១,១00.00 |
| ការកាត់កងប្រាក់ ចំណូលសម្រាប់ កុមារមិនពិការក្នុងខែមករា ឆ្នាំ២០១៦ គឺ $៣៦៧.00 | ការកាត់កងប្រាក់ចំណូល សម្រាប់កុមារមិនពិការក្នុងខែមករា ឆ្នាំ២០១៤ គឺ $៣៦១.00 | ការកាត់កងប្រាក់ ចំណូលសម្រាប់ កុមារមិនពិការក្នុងខែមករា ឆ្នាំ២០១៥ គឺ $៣៦៧.00 |
| អត្រា ចំណូលសន្តិសុខបង្គ្រប់ម្រាប់ កុមារពិការ ក្នុងខែមករា ឆ្នាំ២០១៦ គឺ $៧៩៦.៤0 | អត្រា ចំណូលសន្តិសុខបង្គ្រប់ សម្រាប់កុមារពិការ ក្នុងខែមករា ឆ្នាំ២០១៤ គឺ $៧៨៤.៤0 | អត្រាចំណូលសន្តិសុខបង្គ្រប់ សម្រាប់កុមារពិការ ក្នុងខែមករា ឆ្នាំ២០១៥ គឺ $៧៩៦.៤0 |
| អត្រាចំណូលសន្តិសុខបង្គ្រប់ សម្រាប់កុមារងងឹតភ្នែក ក្នុងខែមករា ឆ្នាំ២០១៦ គឺ $៩៤៤.៤0 | អត្រាចំណូលសន្តិសុខបង្គ្រប់ សម្រាប់កុមារងងឹតភ្នែក ក្នុងខែមករា ឆ្នាំ២០១៦គឺ $៩៣២.៤0 | អត្រាចំណូលសន្តិសុខបង្គ្រប់ សម្រាប់កុមារងងឹតភ្នែក ក្នុងខែមករា ឆ្នាំ២០១៥ គឺ $៧៩៦.៤0 |

**ឧទាហរណ៍ ក** ៖ លោក និងលោកស្រី ប៉ោម មានកូនចំនួនបីនាក់ បូករួមទាំងអាដាំ ដែលជាក្មេងពិការ ។ ប្រាក់ចំណូលដុល ពីការងាររបស់លោកប៉ោម មានចំនួន $២,000.00 ក្នុងមួយខែ ។ លោកស្រី ប៉ោម ជាបុគ្គលិកធ្វើការក្រៅម៉ោង ហើយប្រាក់ចំណូលដុល របស់គាត់មានចំនួន $១000.00 ក្នុងមួយខែ ។ ពួកគេក៏ទទួលបានចំណូលចំនួន $៣0 ក្នុងមួយខែ ពីការជួលប្រេងឲ្យគេ ។

***ការគណនាបរិមាណប្រាក់ចំណូលរបស់ឪពុកម្ដាយដែលត្រូវ
ចាត់ចូលក្នុងចំណូលសន្តិសុខបង្គ្រប់របស់កុមារ ក្នុងឧទាហរណ៍ ក ៖***

1. បញ្ចូលប្រាក់ចំនួន $៣0.00 ដែលជាប្រាក់ចំណូលក្រៅមុខរបរ បានពីសិទ្ធិជួលរ៉ែឲ្យគេ ក្នុងផ្ទះរបស់ខ្លួន ។

2. នៅក្នុងគ្រួសារនេះ មានកូនចំនួនពីរនាក់ បន្ថែមពីលើកុមារឈ្មោះអាដាំ ។ ចំពោះឧទាហរណ៍នេះ កូនៗទាំងនោះមិនមានប្រាក់ចំណូលរបស់ខ្លួនឡើយ ។ ចំនួនប្រាក់ក្នុងឆ្នាំ ២០១៦ សម្រាប់ក្មេងមិនពិការនៅក្នុងគ្រួសារគឺម្នាក់ៗបានចំនួន $៣៦៧.00 ។ បញ្ចូលទឹកប្រាក់ចំនួន $៧៣៤.00 ដែលវាជាចំនួនប្រាក់កំណត់ឲ្យសរុប សម្រាប់កុមារមិនពិការ ។

3. ក្នុងនេះ គឺមិនមានប្រាក់ចំណូលក្រៅមុខរបរ ដែលត្រូវយកមកគិតក្នុងការកាត់កងប្រាក់ចំណូលណាមួយឡើយ ។

4. ប្រាក់ចំណូលសរុបក្រៅការងារដែលរាប់បាន ប្រាកដណាស់ គឺមានចំនួនស្មើនឹងសូន្យ ។

5. ប្រាក់ចំណូលដុលពីការងារបញ្ចូលគ្នាសរុប សម្រាប់អ្នកទាំងពីរ គឺលោក និងលោកស្រី ប៉ោម គឺ $៣,000.00 ($២,000.00 បូកនឹង $១,000.00) ។

6. សមតុល្យដែលមិនបានប្រើ នៃប្រាក់ដែលចាត់ឲ្យ (បន្ទាត់លេខ ១ ដកនឹង បន្ទាត់លេខ ២) សម្រាប់កុមារមិនពិការ នៅក្នុងគ្រួសារគឺមានចំនួន $៧0៤.00 ។

7. ដោយសារអ្នកមិនអាចឈានដល់ចំនួន $២0.00 នៃប្រាក់ចំណូលណាមួយ ដែលមិនបានគិតដល់ ក្នុងបន្ទាត់លេខ ៣ ខាងលើ ដែលជាការកាត់កងពេញលេញចំនួន $២0.00 ត្រូវយកមកបញ្ចូលក្នុងទីនេះ ។

8. បន្ទាប់មក អ្នកត្រូវដកចំនួន $៦៥.00 ជាការកាត់កងប្រាក់ចំណូលពីការងារ ។

9. ចំនួនសរុបរងរបស់អ្នកគឺ $២,២១១.00 ($៣,000.00 ដកនឹង $៧0៤.00, ដកនឹង $២0.00 ហើយដកនឹង $៦៥.00) ។

10. អ្នកត្រូវសរសេរចូលចំនួន $១,១0៥.៥0 ដែលជាចំនួនពាក់កណ្តាលនៃបន្ទាត់លេខ ៩ ។

11. ចំនួនប្រាក់ចំណូលសរុបពីការងាររបស់អ្នកដែលរាប់បានគឺ $១,១0៥.៥0 ។

12. ដោយសារវាមិនមានប្រាក់ចំណូលរាប់បានក្រៅមុខរបរ ពីបន្ទាត់លេខ៤ ខាងលើ ចំនួនប្រាក់ចំណូលរាប់បានសរុបក៏មានចំនួន $១,១0៥.៥0 ផងដែរ ។

13. អត្រាអត្ថប្រយោជន៍សហព័ន្ធសម្រាប់ប្តីប្រពន្ធ ក្នុងឆ្នាំ២០១៦ គឺ $១១00.00 ។

14. ចំនួនប្រាក់ដែលចាត់ជាប្រាក់ចំណូលសម្រាប់កុមារពិការ គឺជា ចំនួនប្រាក់ចំណូលសរុបដែលរាប់បាន ដកនឹងអត្រាអត្ថប្រយោជន៍សហព័ន្ធសម្រាប់ប្តីប្រពន្ធ ឬចំនួន $៥.៥0 ។

***ការគណនាប្រាក់ឧបត្ថម្ភរបស់កុមារ ក្នុងឧទាហរណ៍ ក ៖***

a. ក្នុងខែមករា ឆ្នាំ២០១៦ កម្រិតប្រាក់ឧបត្ថម្ភ សម្រាប់ចំណូលសន្តិសុខបង្គ្រប់របស់កុមារពិការគឺ $៧៩៦.៤0 ។

b. ទឹកប្រាក់ដែលចាត់ចូលជាប្រាក់ចំណូលរបស់កុមារគឺ $៥.៥0 ហើយគឺមិនមានប្រាក់ចំណូលក្រៅមុខរបរណាផ្សេងទៀត (ដូចជាប្រាក់ចំណូល Title II ស្តីអំពីអត្ថប្រយោជន៍បេឡាសន្តិសុខបង្គ្រប់ចំពោះអ្នកនៅក្នុងបន្ទុក) ។

c. នៅក្នុងឧទាហរណ៍នេះ គឺមិនមានប្រាក់ចំណូលចំពោះការឧបត្ថម្ភ កុមារឡើយ ។

d. អ្នកត្រូវដកចេញចំនួន $២0.00 ចំពោះប្រាក់ចំណូលណាមួយដែលមិនបានគិតដល់ ពីប្រាក់ចំណូល របស់កុមារ ។

e. កុមារនេះ មិនមានប្រាក់ចំណូលពីការងារឡើយ ក្នុងឧទាហរណ៍នេះ ។

f. ចំនួនប្រាក់ចំណូលរាប់បានសរុបរបស់កុមារគឺ $0 ($៥.៥0 ដកនឹងប្រាក់ដែលអនុញ្ញាតចំនួន $២0.00 ចំពោះការកាត់កងប្រាក់ចំណូលណាមួយ) ។

g. ទឹកប្រាក់ក្នុងសែកចំណូលសន្តិសុខបង្គ្រប់របស់កុមារគឺត្រូវជា $៧៩៦.៤0 ។

**ឧទាហរណ៍ ក**
**តារាងប្រាក់ចាត់ជាប្រាក់ចំណូលរបស់កុមារក្នុងបេឡាសន្តិសុខបង្គ្រប់របស់ឪពុកម្តាយ-កូន ប្រចាំខែ**

*ប្រាក់ចំណូលរបស់ឪពុកម្តាយ ៖*

| | | | |
|---|---|---|---|
| 1. | ប្រាក់ចំណូលក្រៅមុខរបរ | $៣0.00 | $0.00 |
| 2. | ដកនឹងប្រាក់លែទុកសម្រាប់កូន[1] ដទៃ | $(៧៣៤.00) | $0.00 |
| 3. | ដកនឹង $២0 ចំពោះប្រាក់ចំណូលណាមួយ ដែលមិនបានគិតដល់ | $(២0.00) | $0.00 |
| 4. | សរុបប្រាក់ចំណូលក្រៅការងារដែលរាប់បាន | $0.00 | $0.00 |
| 5. | សរុបប្រាក់ចំណូលដុលពីការងារ | $៣,000.00 | $0.00 |
| 6. | ដកនឹងប្រាក់សមតុល្យសម្រាប់កុមារផ្សេងទៀត (2 ដក 1)[2] | $(៧0៤.00) | $0.00 |
| 7. | ដកនឹងសមតុល្យនៃប្រាក់ចំណូលណាមួយដែល | | |

[1] ប្រាក់លៃសម្រាប់កុមារមិនពិការម្នាក់ៗ មានចំនួន $៣៥៦.00 សម្រាប់ខែមករា ឆ្នាំ២០១៣, $៣៦១.00 សម្រាប់ឆ្នាំ២០១៤ ហើយនិង $៣៦៧.00 សម្រាប់ឆ្នាំ ២០១៥ និង ២០១៦ ។ ចំនួនប្រាក់ដែលអាចកាត់កងបាន សម្រាប់កុមារផ្សេងទៀត អាចត្រូវកាត់បន្ថយទៅតាមប្រាក់ចំណូលរបស់កុមារទាំងនោះ ។ ប្រាក់ដែលអាចកាត់កងបាន ដែលមិនបានប្រើក្នុងបន្ទាត់លេខ ២ នឹងត្រូវកាត់ចេញពីប្រាក់ចំណូលបានពីមុខរបរ ក្នុងបន្ទាត់លេខ ៦ ។ "ត្រឡប់ទៅកាន់ឯកសារដើមវិញ"

[2] ប្រាក់លៃសម្រាប់កុមារមិនពិការម្នាក់ៗ មានចំនួន $៣៥៦.00 សម្រាប់ខែមករា ឆ្នាំ២០១៣, $៣៦១.00 សម្រាប់ឆ្នាំ២០១៤ ហើយនិង $៣៦៧.00 សម្រាប់ឆ្នាំ ២០១៥ និង ២០១៦ ។ ចំនួនប្រាក់ដែលអាចកាត់កងបាន សម្រាប់កុមារផ្សេងទៀត អាចត្រូវកាត់បន្ថយទៅតាមប្រាក់ចំណូលរបស់កុមារទាំងនោះ ។ ប្រាក់ដែលអាចកាត់កងបាន ដែលមិនបានប្រើក្នុងបន្ទាត់លេខ ២ នឹងត្រូវកាត់ចេញពីប្រាក់ចំណូលបានពីមុខរបរ ក្នុងបន្ទាត់លេខ ៦ ។ "ត្រឡប់ទៅកាន់ឯកសារដើមវិញ"

| | | | |
|---|---|---|---|
| | មិនបានគិតដល់ | $(២0.00) | $0.00 |
| 8. | ដកនឹងចំនួន $៦៥.00 នៃប្រាក់ចំណូលពីការងារដែលមិនបានគិតដល់ | $(៦៥.00) | $0.00 |
| 9. | សរុបរង | $២,២១១.00 | $0.00 |
| 10. | ដកនឹងពាក់កណ្តាល (៥0%) នៃចំនួនសរុបរងក្នុងបន្ទាត់ លេខ ៩ | $១,១0៥.៥0 | $0.00 |
| 11. | សរុបប្រាក់ចំណូលពីការងារដែលរាប់បាន | $0.00 | $១,១0៥.៥0 |
| 12. | សរុបរង - ប្រាក់ចំណូលដែលរាប់បាន | $0.00 | $១,១0៥.៥0 |
| 13. | ដកនឹងអត្រាអត្ថប្រយោជន៍សហព័ន្ធ[3] សម្រាប់បុគ្គល ឬប្ដីប្រពន្ធ | $0.00 | $(១១00.00) |
| 14. | ចំនួនប្រាក់ចាត់ចូលជាប្រាក់ចំណូលចំពោះក្មេង[4] ពិការ | $0.00 | $៥.៥0 |

***ការគណនាប្រាក់ឧបត្ថម្ភកុមារ៖***

| | | | |
|---|---|---|---|
| a. | កម្រិត[5]ប្រាក់ឧបត្ថម្ភចំណូលសន្តិសុខបង្គ្រប់របស់កុមារ | $0.00 | $៧៩៦.៥0 |

---

[3] អត្រាអត្ថប្រយោជន៍សហព័ន្ធសម្រាប់បុគ្គល (អត្រាអត្ថប្រយោជន៍សហព័ន្ធ) ក្នុងឆ្នាំ ២០១៣ គឺ $៧១0.00,

$៧២១.00 សម្រាប់ឆ្នាំ ២០១៤ និង $៧៣៣.00 សម្រាប់ឆ្នាំ ២០១៥ និង ២០១៦ ។ អត្រាអត្ថប្រយោជន៍សហព័ន្ធសម្រាប់ប្ដីប្រពន្ធ ក្នុងឆ្នាំ ២០១៣ គឺ $១0៦៦.00, $១0៨២.00 ក្នុងឆ្នាំ ២០១៤ និង $១១00.00 សម្រាប់ឆ្នាំ ២0១៥ និង ២០១៦ ។

"ត្រឡប់ទៅកាន់ឯកសារដើមវិញ"

[4] ប្រសិនបើអ្នកមានកូនពិការច្រើនជាងមួយនាក់ ប្រាក់ដែលចាត់សម្រាប់ជាប្រាក់ចំណូលរបស់កុមារទាំងនេះ ត្រូវបែងចែកក្នុងចំណោមក្មេងពិការទាំងនោះ ។ "ត្រឡប់ទៅកាន់ឯកសារដើមវិញ"

[5] អត្រាប្រាក់ចំណូលសន្តិសុខបង្គ្រប់របស់កុមារពិការនៅរដ្ឋកាលីហ្វ័រនីញ៉ា បូករួមទាំងអត្រាអត្ថប្រយោជន៍សហព័ន្ធ និងប្រាក់បង្គ្រប់របស់រដ្ឋក្នុងឆ្នាំ ២0១៣ គឺ $៧៧៣.៥0, $៧៨៥.៥0 ក្នុងឆ្នាំ ២០១៤ និង $៧៩៦.៥0 ក្នុងឆ្នាំ ២០១៥ និងឆ្នាំ ២០១៦ ។

| | | | |
|---|---|---|---|
| b. | ទឹកប្រាក់ចាត់ចូលជាប្រាក់ចំណូលរបស់កុមារពីលេខ បន្ទាត់លេខ ១៤ ខាងលើ បូកនឹងប្រាក់ចំណូលក្រៅមុខ របរផ្សេងទៀត | $៥.៥0 | $0.00 |
| c. | ២/៣ នៃប្រាក់ឧបត្ថម្ភ[6] ក្មេងណាម្នាក់ | $0.00 | $0.00 |
| d. | ដកនឹង $២0.00 ចំពោះប្រាក់ចំណូលណាមួយដែលមិន បានគិតដល់ | $(២0.00) | $0.00 |
| e. | ប្រាក់ចំណូល[7]ពីការងារដែលរាប់បាន | $0.00 | $0.00 |
| f. | សរុបប្រាក់ចំណូលរាប់បានរបស់កុមារ | $0.00 | $0.00 |
| g. | ប្រាក់ឧបត្ថម្ភកុមារពីចំណូលបេឡាសន្តិសុខបង្គ្រប់ | $0.00 | $៧៩៦.៤0 |

**ឧទាហរណ៍ ខ** ៖ បេទី បាតុន គឺជាម្ដាយទោល ដែលមានកូនពិការឈ្មោះ ប៊ិល ។ កុមារប៊ិល ទទួលបានប្រាក់ឧបត្ថម្ភពីឪពុករបស់ខ្លួនចំនួន $២២៥.00 ក្នុងមួយខែ ជាប្រាក់អាហារកិច្ច ។ លោកស្រី បាតុន រកចំណូលបាន $២,000.00 ក្នុងមួយខែ មុនការកាត់កងផ្សេងៗ ។

***ការគណនាចំនួនប្រាក់ចំណូលរបស់ឪពុកម្ដាយ ដើម្បីចាត់ចូលទៅក្នុង ចំណូលបេឡាសន្តិសុខបង្គ្រប់របស់កុមារ ក្នុងឧទាហរណ៍ ខ ៖***

1-4. ។នៅក្នុងឧទាហរណ៍នេះ
គឺមិនមានប្រាក់ចំណូលក្រៅការងារឡើយ ។

---

កុមារពិការភ្នែកមានចំនួន $៩២១.៤0 សម្រាប់ ឆ្នាំ ២០១៣, $៩៣២.៤0 សម្រាប់ឆ្នាំ ២០១៤ និង $៩៤៤.៤0 សម្រាប់ឆ្នាំ ២០១៥ និងឆ្នាំ ២០១៦ ។ "ត្រឡប់ទៅកាន់ឯកសារដើមវិញ"

[6] គឺមានតែពីរភាគបីនៃប្រាក់ឧបត្ថម្ភកុមារទេដែលត្រូវរាប់បញ្ចូល ។

"ត្រឡប់ទៅកាន់ឯកសារដើមវិញ"

[7] ក្នុងឆ្នាំ ២០១៣ ចំនួនប្រាក់លើកលែងប្រចាំខែគឺ $១,៧៣0.00 ហើយចំនួនប្រាក់លើកលែងប្រចាំឆ្នាំមានចំនួន $៦,៩៦0.00 ។ ក្នុងឆ្នាំ ២០១៤ ចំនួនប្រាក់លើកលែងប្រចាំខែមានចំនួន $១៧៥0.00 ហើយចំនួនប្រាក់លើកលែងប្រចាំឆ្នាំមានចំនួន $៧,០៦0 ។ ក្នុងឆ្នាំ ២០១៥ និងឆ្នាំ២០១៦ ចំនួនប្រាក់លើកលែងប្រចាំខែមានចំនួន $១៧៨0.00 ហើយចំនួនប្រាក់លើកលែងប្រចាំឆ្នាំមានចំនួន $៧១៨0.00 ។ លើសពីនេះ កុមារត្រូវរងការកាត់កងសម្រាប់ប្រាក់ចំណូលពីការងារទាំងអស់របស់មនុស្សធំ ។

"ត្រឡប់ទៅកាន់ឯកសារដើមវិញ"

5. ប្រាក់ចំណូលដុលពីការងារមានចំនួន $២,000.00 ក្នុងមួយខែ ។

6. នៅក្នុងឧទាហរណ៍ គ្រួសារនេះមិនមាន កុមារផ្សេងទៀតឡើយ ។

7. ដោយសារគ្រួសារនេះ មិនមានប្រាក់ចំណូលក្រៅការងារ គឺត្រូវកាត់កង $២0.00 ពេញ ចំពោះប្រាក់ចំណូលណាមួយដែលមិនបានគិតនៅទីនេះ ។

8. បន្ទាប់មក អ្នកត្រូវដកចំនួន $៦៥.00 ជាការកាត់កងប្រាក់ចំណូលពីការងារ ។

9. ចំនួនសរុបរងគឺ $១,៩១៥.00 -- $២,000.00 ដកនឹង $២0.00 (លេខ ៧) និង $៦៥.00 (បន្ទាត់លេខ ៨) ដែលជាការមិនគិតដល់ ។

10. ដកពាក់កណ្តាលនៃចំនួន $១,៩១៥.00 ឬ $៩៥៧.៥0 ។

11. សរុបប្រាក់ចំណូលពីការងារដែលរាប់បានក៏មានចំនួនស្មើនឹង $៩៥៧.៥0 ផងដែរ ។

12. សរុបប្រាក់ចំណូលពីការងារដែលរាប់បានគឺ $៩៥៧.៥0 គឺដោយសារមិនមានប្រាក់ចំណូលក្រៅការងារ នៅក្នុងឧទាហរណ៍នេះ ។

13. អត្រាអត្ថប្រយោជន៍សហព័ន្ធ សម្រាប់ប្តី/ប្រពន្ធទោលក្នុងឆ្នាំ ២០១៦ គឺ $៧៣៣.00 ។

14. ចំនួនទឹកប្រាក់ត្រូវចាត់ចូលជាប្រាក់ចំណូលសម្រាប់ប៊ិលគឺ $២២៤.៥0 ដែលជាផលដករវាងចំនួន $៩៥៧.៥0 និង $៧៣៣.00 ។

***ការគណនាប្រាក់ឧបត្ថម្ភកុមារ ក្នុងឧទាហរណ៍ ខ៖***

a. កម្រិតប្រាក់ឧបត្ថម្ភកុមារក្នុងខែមករា ឆ្នាំ២០១៦ គឺ $៧៩៦.៤0 ។

b. ចំនួនប្រាក់ចាត់ចូលជាប្រាក់ចំណូលរបស់កុមារគឺ $២២៤.៥0 ។ មិនមានប្រាក់ចំណូលក្រៅមុខរបរ ដូចជាជំនួយ Title II ចំពោះអត្ថប្រយោជន៍បេឡាសន្តិសុខសង្គមរបស់អ្នកនៅក្នុងបន្ទុកទេ ។

c. នៅក្នុងឧទាហរណ៍នេះ កុមារប៊ិល ទទួលបានប្រាក់អាហារកិច្ចចំនួន $២២៥.00 ក្នុងមួយខែ ពីឪពុករបស់ខ្លួន ។ បេឡាសន្តិសុខសង្គម គឺរាប់បញ្ចូលតែពីរភាគបីនៃប្រាក់អាហារកិច្ច មួយភាគបីនៃចំនួន $២២៥ ឬ $៧៥ ត្រូវដកចេញពីចំនួន $២២៥ ហើយសមតុល្យ ឬចំនួន $១៥0 គឺត្រូវរាប់ជាប្រាក់ចំណូលរបស់កុមារ ។

d. អ្នកត្រូវដកចេញចំនួន $២0.00 ចំពោះប្រាក់ចំណូលណាមួយដែលមិនបានគិតដល់ ពីប្រាក់ចំណូលរបស់កុមារ ។

e. នៅក្នុងឧទាហរណ៍ កុមាររូបនេះ មិនមានប្រាក់ចំណូលពីការងារឡើយ ។

f. ប្រាក់ចំណូលក្រៅមុខរបរដែលរាប់បានរបស់កុមារគឺ $៣៥៤.៥0 ($២២៤.៥0 បូកនឹង $១៥0.00 ដកនឹង $២0.00) ។

g. ប្រាក់ឧបត្ថម្ភកុមារពីចំណូលសន្តិសុខបង្គ្រប់គឺ $៤៤១.៩0 ($៧៩៦.៤0 ដកនឹង $៣៥៤.៥0)

**ឧទាហរណ៍ ខ**
**តារាងប្រាក់ចាត់ជាប្រាក់ចំណូលរបស់កុមារក្នុងបេឡាសន្តិសុខបង្គ្រប់របស់ឪពុកម្តាយ-កូន ប្រចាំខែ**

***ប្រាក់ចំណូលរបស់ឪពុកម្តាយ ៖***

| | | |
|---|---|---|
| 1. ប្រាក់ចំណូលក្រៅមុខរបរ | $0.00 | $0.00 |
| 2. ដកនឹងប្រាក់លែទុកសម្រាប់កុមារ[8] ដទៃ | $0.00 | $0.00 |

[8] ប្រាក់លៃសម្រាប់កុមារមិនពិការម្នាក់ៗ មានចំនួន $៣៥៦.00 សម្រាប់ខែមករា ឆ្នាំ២០១៣, $៣៦១.00 សម្រាប់ឆ្នាំ២០១៤ ហើយនិង $៣៦៧.00 សម្រាប់ឆ្នាំ ២០១៥ និង ២០១៦ ។ ចំនួនប្រាក់ដែលអាចកាត់កងបាន សម្រាប់កុមារផ្សេងទៀត អាចត្រូវកាត់បន្ថយទៅតាម

| | | |
|---|---|---|
| 3. ដកនឹង $២0 ចំពោះប្រាក់ចំណូលណាមួយដែលមិនបាន គិតដល់ | $(២0.00) | $0.00 |
| 4. សរុបប្រាក់ចំណូលក្រៅការងារដែលរាប់បាន | $0.00 | $0.00 |
| 5. សរុបប្រាក់ចំណូលដុលពីការងារ | $២,000.00 | $0.00 |
| 6. ដកនឹងសមតុល្យសម្រាប់កុមារ[9] ផ្សេង | $0.00 | $0.00 |
| 7. ដកនឹងសមតុល្យនៃប្រាក់ចំណូលណាមួយដែលមិន បានគិតដល់ | $(២0.00) | $0.00 |
| 8. ដកនឹងចំនួន $៦៥.00 នៃប្រាក់ចំណូលពីការងារដែលមិន បានគិតដល់ | $($៦៥.00) | $0.00 |
| 9. សរុបរង | $១,៩១៥.00 | $0.00 |
| 10. ដកនឹងពាក់កណ្ដាល (៥0%) នៃចំនួនសរុបរងក្នុងបន្ទាត់ លេខ ៩ | $(957.៥0) | $0.00 |
| 11. សរុបប្រាក់ចំណូលពីការងារដែលរាប់បាន | $0.00 | $៩៥៧.៥0 |
| 12. សរុបរង - ប្រាក់ចំណូលដែលរាប់បាន | $0.00 | $៩៥៧.៥0 |
| 13. ដកនឹងអត្រាអត្ថប្រយោជន៍សហព័ន្ធ[10] សម្រាប់បុគ្គល | | |

---

ប្រាក់ចំណូលរបស់កុមារទាំងនោះ ។ ប្រាក់ដែលអាចកាត់កងបាន ដែលមិនបានប្រើក្នុងបន្ទាត់លេខ ២ នឹងត្រូវកាត់ចេញពីប្រាក់ចំណូលបានពីមុខរបរ ក្នុងបន្ទាត់លេខ ៦ ។ "ត្រឡប់ទៅកាន់ឯកសារដើមវិញ"

[9] ប្រាក់លៃសម្រាប់កុមារមិនពិការម្នាក់ៗ មានចំនួន $៣៥៦.00 សម្រាប់ខែមករា ឆ្នាំ២០១៣, $៣៦១.00 សម្រាប់ឆ្នាំ២០១៤ ហើយនិង $៣៦៧.00 សម្រាប់ឆ្នាំ ២០១៥ និង ២០១៦ ។ ចំនួនប្រាក់ដែលអាចកាត់កងបាន សម្រាប់កុមារផ្សេងទៀត អាចត្រូវកាត់បន្ថយទៅតាម ប្រាក់ចំណូលរបស់កុមារទាំងនោះ ។ ប្រាក់ដែលអាចកាត់កងបាន ដែលមិនបានប្រើក្នុងបន្ទាត់លេខ ២ នឹងត្រូវកាត់ចេញពីប្រាក់ចំណូលបានពីមុខរបរ ក្នុងបន្ទាត់លេខ ៦ ។ "ត្រឡប់ទៅកាន់ឯកសារដើមវិញ"

[10] អត្រាអត្ថប្រយោជន៍សហព័ន្ធសម្រាប់បុគ្គល (អត្រាអត្ថប្រយោជន៍សហព័ន្ធ) ក្នុងឆ្នាំ ២០១៣ គឺ $៧១0.00, $៧២១.00 សម្រាប់ឆ្នាំ ២០១៤ និង $៧៣៣.00 សម្រាប់ ឆ្នាំ ២០១៥ និង២០១៦ ។ អត្រាអត្ថប្រយោជន៍សហព័ន្ធសម្រាប់ប្ដីប្រពន្ធ ក្នុងឆ្នាំ ២០១៣ គឺ $១០៦៦.00, $១០៨២.00 ក្នុងឆ្នាំ ២០១៤ និង $១១00.00 សម្រាប់ឆ្នាំ ២0១៥ និង ២០១៦ ។

"ត្រឡប់ទៅកាន់ឯកសារដើមវិញ"

ឬប្តីប្រពន្ធ $0.00 $(៧៣៣.00)

14. ចំនួនប្រាក់ចាត់ចូលជាប្រាក់ចំណូលចំពោះក្មេង[11]ពិការ $0.00 $២២៤.៥0

*ការគណនាប្រាក់ឧបត្ថម្ភកុមារ៖*

a. កម្រិត[12]ប្រាក់ឧបត្ថម្ភចំណូលសន្តិសុខបង្គ្រប់របស់កុមារ $0.00 $៧៩៦.៤0

b. ចំនួនប្រាក់ចាត់ជាប្រាក់ចំណូលសម្រាប់កុមារចេញពីបន្ទាត់លេខ ១៤ ខាងលើ បូកនឹង ប្រាក់ចំណូលក្រៅមុខរបរ $២២៤.៥0 $0.00

c. ២/៣ នៃប្រាក់ឧបត្ថម្ភ[13] កូនណាម្នាក់ $១៥0.00 $0.00

d. ដកនឹង $២0.00 ចំពោះប្រាក់ចំណូលណាមួយដែលមិនបានគិតដល់ $(២0.00) $0.00

e. ប្រាក់ចំណូល[14] ពីការងារដែលរាប់បាន $0.00 $0.00

---

[11] ប្រសិនបើអ្នកមានកូនពិការច្រើនជាងមួយនាក់ ប្រាក់ដែលចាត់សម្រាប់ជាប្រាក់ចំណូលរបស់កុមារទាំងនេះ ត្រូវបែងចែកក្នុងចំណោមក្មេងពិការទាំងនោះ ។ "ត្រឡប់ទៅកាន់ឯកសារដើមវិញ"

[12] អត្រាប្រាក់ចំណូលសន្តិសុខបង្គ្រប់របស់កុមារពិការនៅរដ្ឋកាលីហ្វ័រនីញ៉ា បូករួមទាំងអត្រាអត្ថប្រយោជន៍សហព័ន្ធ និងប្រាក់បង្គ្រប់របស់រដ្ឋក្នុងឆ្នាំ ២០១៣ គឺ $៧៧៣.៤0, $៧៨៩.៤0 ក្នុងឆ្នាំ ២០១៤ និង $៧៩៦.៤0 ក្នុងឆ្នាំ ២០១៥ និងឆ្នាំ ២០១៦ ។ កុមារពិការភ្នែកមានចំនួន $៩២១.៤0 សម្រាប់ ឆ្នាំ ២០១៣, $៩៣២.៤0 សម្រាប់ឆ្នាំ ២០១៤ និង $៩៤៤.៤0 សម្រាប់ឆ្នាំ ២០១៥ និងឆ្នាំ ២០១៦ ។ "ត្រឡប់ទៅកាន់ឯកសារដើមវិញ"

[13]គឺមានតែពីរភាគបីនៃប្រាក់ឧបត្ថម្ភកុមារទេដែលត្រូវរាប់បញ្ចូល ។ "ត្រឡប់ទៅកាន់ឯកសារដើមវិញ" (Return to Main Document)

[14] ក្នុងឆ្នាំ ២០១៣ ចំនួនប្រាក់លើកលែងប្រចាំខែគឺ $១,៧៣0.00 ហើយចំនួនប្រាក់លើកលែងប្រចាំឆ្នាំមានចំនួន $៦,៩៦0.00 ។ ក្នុងឆ្នាំ ២០១៤ ចំនួនប្រាក់លើកលែងប្រចាំខែមានចំនួន $១៧៥0.00 ហើយចំនួនប្រាក់លើកលែងប្រចាំឆ្នាំមានចំនួន $៧,០៦0 ។ ក្នុងឆ្នាំ ២០១៥ និងឆ្នាំ២០១៦ ចំនួនប្រាក់លើកលែងប្រចាំខែមានចំនួន $១៧៨0.00 ហើយ

| | | | |
|---|---|---|---|
| f. | សរុបប្រាក់ចំណូលរាប់បានរបស់កុមារ | $0.00 | $៣៥៤.៥0 |
| g. | ប្រាក់ឧបត្ថម្ភចំណូលសន្តិសុខបង្គ្រប់របស់កុមារ | $0.00 | $៤៤១.៩0 |

***តារាងទំនេរសម្រាប់ការ***
***ចាត់ប្រាក់ចំណូលសម្រាប់កុមារនៃរបបសន្តិសុខសង្គមប្រចាំខែរបស់ឪពុកម្តាយ-កូន***

***ប្រាក់ចំណូលរបស់ឪពុកម្តាយ៖***

| | | | |
|---|---|---|---|
| 1. | ប្រាក់ចំណូលក្រៅមុខរបរ | $0.00 | $0.00 |
| 2. | ដកនឹងប្រាក់លៃទុកសម្រាប់ កូន[15] ផ្សេងទៀត | $( ) | $0.00 |
| 3. | ដកនឹង $២0 ចំពោះប្រាក់ចំណូលណាមួយដែលមិនបានគិតដល់ | $(២0.00) | $0.00 |
| 4. | សរុបប្រាក់ចំណូលក្រៅការងារដែលរាប់បាន | $0.00 | $0.00 |
| 5. | សរុបប្រាក់ចំណូលដុលពីការងារ | $0.00 | $0.00 |
| 6. | ដកនឹងសមតុល្យសម្រាប់ កូន[16] ផ្សេងទៀត | $( ) | $0.00 |

---

ចំនួនប្រាក់លើកលែងប្រចាំឆ្នាំមានចំនួន $៧១៨0.00 ។ លើសពីនេះ កុមារត្រូវរងការកាត់កងសម្រាប់ប្រាក់ចំណូលពីការងារទាំងអស់របស់មនុស្សធំ ។
"ត្រឡប់ទៅកាន់ឯកសារដើមវិញ"

[15] ប្រាក់លៃសម្រាប់កុមារមិនពិការម្នាក់ៗ មានចំនួន $៣៥៦.00 សម្រាប់ខែមករា ឆ្នាំ២០១៣, $៣៦១.00 សម្រាប់ឆ្នាំ២០១៤ ហើយនិង $៣៦៧.00 សម្រាប់ឆ្នាំ ២០១៥ និង ២០១៦ ។ ចំនួនប្រាក់ដែលអាចកាត់កងបាន សម្រាប់កុមារផ្សេងទៀត អាចត្រូវកាត់បន្ថយទៅតាមប្រាក់ចំណូលរបស់កុមារទាំងនោះ ។ ប្រាក់ដែលអាចកាត់កងបាន ដែលមិនបានប្រើក្នុងបន្ទាត់លេខ ២ នឹងត្រូវកាត់ចេញពីប្រាក់ចំណូលបានពីមុខរបរក្នុងបន្ទាត់លេខ ៦ ។ "ត្រឡប់ទៅកាន់ឯកសារដើមវិញ"

[16] ប្រាក់លៃសម្រាប់កុមារមិនពិការម្នាក់ៗ មានចំនួន $៣៥៦.00 សម្រាប់ខែមករា ឆ្នាំ២០១៣, $៣៦១.00 សម្រាប់ឆ្នាំ២០១៤ ហើយនិង $៣៦៧.00 សម្រាប់ឆ្នាំ ២០១៥ និង ២០១៦ ។ ចំនួនប្រាក់ដែលអាចកាត់កងបាន សម្រាប់កុមារផ្សេងទៀត អាចត្រូវកាត់បន្ថយទៅតាមប្រាក់ចំណូលរបស់កុមារទាំងនោះ ។ ប្រាក់ដែលអាចកាត់កងបាន

| | | |
|---|---|---|
| 7. ដកនឹងសមតុល្យនៃប្រាក់ចំណូលណាមួយដែលមិនបានគិតដល់ | $(២0.00) | $0.00 |
| 8. ដកនឹងចំនួន $៦៥.00 នៃប្រាក់ចំណូលពីការងារដែលមិនបានគិតដល់ | $(៦៥.00) | $0.00 |
| 9. សរុបរង | $0.00 | $0.00 |
| 10. ដកនឹងពាក់កណ្តាល (៥0%) នៃចំនួនសរុបរងក្នុងបន្ទាត់ លេខ ៩ | $(    ) | $0.00 |
| 11. សរុបប្រាក់ចំណូលពីការងារដែលរាប់បាន | $0.00 | $0.00 |
| 12. សរុបរង - ប្រាក់ចំណូលដែលរាប់បាន | $0.00 | $0.00 |

---

ដែលមិនបានប្រើក្នុងបន្ទាត់លេខ ២ នឹងត្រូវកាត់ចេញពីប្រាក់ចំណូលបានពីមុខរបរ ក្នុងបន្ទាត់លេខ ៦ ។ "ត្រឡប់ទៅកាន់ឯកសារដើមវិញ"

13. ដកនឹងអត្រាអត្ថប្រយោជន៍សហព័ន្ធ[17] សម្រាប់បុគ្គល ឬប្ដីប្រពន្ធ
$0.00 $( )

14. ចំនួនប្រាក់ចាត់ជាប្រាក់ចំណូលសម្រាប់កុមារពិការ
$0.00 $0.00

*ការគណនាប្រាក់ឧបត្ថម្ភកុមារ*

a. កម្រិតចំនួនប្រាក់ចំណូលសន្តិសុខបង្គ្រប់សម្រាប់កុមារ
$0.00 $0.00

b. ទឹកប្រាក់ចាត់ចូលជាប្រាក់ចំណូលរបស់កុមារពីលេខបន្ទាត់លេខ ១៤ ខាងលើ បូកនឹងប្រាក់ចំណូលក្រៅមុខរបរផ្សេងទៀត
$0.00 $0.00

c. ២/៣ នៃប្រាក់ឧបត្ថម្ភអាហារកិច្ចណាមួយរបស់ក្មេង
$0.00 $0.00

d. ដកនឹង $២0.00 ចំពោះប្រាក់ចំណូលណាមួយដែលមិនបានគិតដល់
$(២0.00) $0.00

e. ប្រាក់ចំណូលពីការងារដែលរាប់បាន $0.00 $0.00

f. សរុបប្រាក់ចំណូលរាប់បានរបស់កុមារ $0.00 $0.00

g. ប្រាក់ឧបត្ថម្ភចំណូលសន្តិសុខបង្គ្រប់របស់កុមារ $0.00 $0.00

---

[17] អត្រាអត្ថប្រយោជន៍សហព័ន្ធសម្រាប់បុគ្គល (អត្រាអត្ថប្រយោជន៍សហព័ន្ធ) ក្នុងឆ្នាំ ២០១៣ គឺ $៧១0.00, $៧២១.00 សម្រាប់ឆ្នាំ ២០១៤ និង $៧៣៣.00 សម្រាប់ ឆ្នាំ ២០១៥ និង២០១៦ ។ អត្រាអត្ថប្រយោជន៍សហព័ន្ធសម្រាប់ប្ដីប្រពន្ធ ក្នុងឆ្នាំ ២០១៣ គឺ $១០៦៦.00, $១០៨២.00 ក្នុងឆ្នាំ ២០១៤ និង $១១00.00 សម្រាប់ឆ្នាំ ២០១៥ និង ២០១៦ ។

"ត្រឡប់ទៅកាន់ឯកសារដើមវិញ"

កាលបរិច្ឆេទ ៖ _______________

រដ្ឋបាលបេឡាសន្តិសុខសង្គម
ការិយាល័យឪស្រ្តិក
_____________________
_____________________

កម្មវត្ថុ ៖ ____________________ ឈ្មោះកុមារ ៖ _______________________________

លេខបេឡាសន្តិសុខសង្គមរបស់កុមារ ៖ _____________________

អាសយដ្ឋាន ៖ ____________________________________

________________________________________________

លេខទូរស័ព្ទ ៖ __________________________________
ខ្ញុំបាទ/នាងខ្ញុំ (យើងខ្ញុំ) ជាឪពុកម្តាយរបស់កុមារដែលបានបញ្ជាក់ពីខាងលើ ។ នេះជារបាយការណ៍នៃការផ្លាស់ប្តូរប្រាក់ចំណូលសម្រាប់ខែ _________________ ។ ប្រសិនបើការប្រែប្រួលប្រាក់ចំណូលនឹងនាំឲ្យមានការប្រែប្រួលចំនួនប្រាក់ក្នុងសែកសន្តិសុខបង្គ្រប់របស់កូនខ្ញុំបាទ/នាងខ្ញុំ (យើងខ្ញុំ) សូមមេត្តាជួយប្រាប់ឲ្យខ្ញុំបាទ/នាងខ្ញុំ (យើងខ្ញុំ) បានដឹងផង ។ ខ្ញុំបាទ/នាងខ្ញុំ (យើងខ្ញុំ) សូមស្បថ ឬសូមប្រកាស ក្រោមការពិន័យពីការភូតកុហកថា ការគណនាក្នុងរបាយការណ៍នេះ គឺជាការពិត និងត្រឹមត្រូវ ហើយសំណៅណាមួយដែលបានដាក់ភ្ជាប់មកជាមួយ គឺជាសំណៅត្រឹមត្រូវចេញពីច្បាប់ដើម ។ បានចុះហត្ថលេខាតាមកាលបរិច្ឆេទ និងទីកន្លែងដែលបានបញ្ជាក់ខាងលើ ។

__________________________________________________
ឪពុក

__________________________________________________
ម្តាយ

ប្រាក់ចំណូលពីការងាររបស់ឪពុកម្តាយ
សំណៅថតចម្លងនៃកំណត់ត្រា/សន្លឹកប្រាក់ខែ បានដាក់ភ្ជាប់មកជាមួយ
សំណៅច្បាប់ដើម ត្រូវបានរក្សាទុកសម្រាប់ឲ្យរដ្ឋបាលសន្តិសុខសង្គមធ្វើអធិការកិច្ច
នៅក្នុងពេលពិនិត្យសំណុំរឿងឡើងវិញប្រចាំឆ្នាំ ។
និយោជក ៖ ____________________________
ចំនួន/កាលបរិច្ឆេទបើកប្រាក់ $ _______________
ចំនួន/កាលបរិច្ឆេទបើកប្រាក់ $ _______________
ចំនួន/កាលបរិច្ឆេទបើកប្រាក់ $ _______________
ចំនួន/កាលបរិច្ឆេទបើកប្រាក់ $ _______________
ប្រាក់ចំណូលក្រៅមុខរបរ
ប្រភព ៖ ______________________ ចំនួន/កាលបរិច្ឆេទទទួលប្រាក់ $ ________________

## កំណត់ចំណាំនៅចុងទំព័រ

---

[1] បើទោះបីជាសន្តិសុខសង្គមរាប់បញ្ចូលប្រាក់ចំណូល និងធនធានរបស់ឪពុក/ម្តាយចុងសម្រាប់គោលបំណងគណនាប្រាក់ចំណូលសន្តិសុខបង្គ្រប់ក៏ដោយ ក៏ភ្នាក់ងារកម្មវិធី Medi-Cal រដ្ឋ (Medicaid) មិនអាចរាប់បញ្ចូលបានដែរ ។ ក្រម 42 សហរដ្ឋអាមេរិក វគ្គទី 1396a(a)(17)(D) ។ សម្រាប់កុមារ កម្មវិធី Medi-Cal គិតតែប្រាក់ចំណូល និងធនធានរបស់ឪពុក/ម្តាយ និងកុមារ ។ បើកូនរបស់អ្នកមិនមានលក្ខណៈសម្បត្តិទទួលបានចំណូលសន្តិសុខបង្គ្រប់ដោយសារប្រាក់ចំណូល និងធនធានរបស់ឪពុក/ម្តាយចុង សូមដាក់ពាក្យសុំជំនួយ Medi-Cal ក្រោមកម្មវិធីកម្រិតភាពក្រីក្រសហព័ន្ធ សម្រាប់មនុស្សជរា និងកុមារព្រមទាំងមនុស្សពេញវ័យជាជនពិការ (A&D FPL, Federal Poverty Level for aged and for children and adults with disabilities) ។
បើកូនរបស់អ្នកមិនមានសិទ្ធិទទួលបានជំនួយពីកម្មវិធី មនុស្សជរា និងកុមារព្រមទាំងមនុស្សពេញវ័យជាជនពិការ សូមដាក់ពាក្យសុំជំនួយកម្មវិធី Medi-Cal ក្រោម ជរា-ងងឹត-ពិការ (ABD, aged-blind-disabled) ដែលជាកម្មវិធីសម្រាប់តម្រូវការការថែទាំសុខភាព ។ អ្នកដាក់ពាក្យសុំជំនួយ Medi-Cal នៅឯការិយាល័យសុខុមាលភាពខោនធី របស់អ្នក ។ សូមពន្យល់ថា កូនរបស់អ្នកគឺជាអ្នកនៅក្នុងសំណុំរឿង *Sneede* (ឈ្មោះសំណុំរឿងក្តី) ដើម្បីធានាថាបទបញ្ញត្តដែលត្រឹមត្រូវ ត្រូវបានប្រើ ។
"ត្រឡប់ទៅកាន់ឯកសារដើមវិញ"

[2] ដើម្បីទទួលបានចំណូលសន្តិសុខបង្គ្រប់សម្រាប់កូនរបស់អ្នកឡើងវិញ សូមសរសេរសំបុត្រ
ឬសូមមកកាន់ការិយាល័យបេឡាសន្តិសុខសង្គមប្រចាំមូលដ្ឋានរបស់អ្នក ដើម្បីរាយការណ៍អំពីការថយចុះនូវប្រាក់ចំណូល ឬរាយការណ៍អំពីធនធនរបស់អ្នក ថាបច្ចុប្បន្ន បានចុះមកក្នុងដែនកំណត់បេឡាសន្តិសុខសង្គម ។ រួមបញ្ចូលនូវឯកសារដែលបង្ហាញថា ប្រាក់ចំណូលរបស់អ្នក ឥឡូវមានបរិមាណទាប ឬថាបច្ចុប្បន្ន ធនធានរបស់អ្នកស្ថិតនៅក្នុងដែនកំណត់របស់ចំណូលសន្តិសុខបង្គ្រប់ ។ អ្នកត្រូវសុំជាពិសេសឲ្យផ្តល់ជូននូវសិទ្ធិទទួលបានចំណូលសន្តិសុខបង្គ្រប់វិញ ។
បើអ្នកស្នើសុំការផ្តល់សិទ្ធិទទួលបានចំណូលសន្តិសុខបង្គ្រប់ឲ្យដូចដើមវិញ តាមប្រៃសនី យើងខ្ញុំសូមណែនាំអ្នកឲ្យធ្វើបែបនេះតាមរយៈប្រៃសនីដែលមានការបញ្ជាក់ត្រឹមត្រូវ ។ "ត្រឡប់ទៅកាន់ឯកសារដើមវិញ"

[3] ការផ្លាស់ប្តូរប្រាក់ចំណូល គឺមិនមែនជារបស់តែមួយមុខ ដែលអ្នកត្រូវរាយការណ៍ឡើយ ។ *សូមអាន* ក្រម 20 នៃបទបញ្ញត្តិសហព័ន្ធវគ្គទី 416.708 ។ អ្នកត្រូវប្រាប់បេឡាសន្តិសុខសង្គម ឲ្យបានដឹង បើអ្នកប្តូរទីលំនៅ បើកូនពិការ ឬកូនមិនពិការរបស់អ្នកដូរទៅរស់នៅកន្លែងផ្សេង ប្រសិនបើឪពុក/ម្តាយរៀបការ បើឪពុក ឬម្តាយត្រូវរើចេញពីផ្ទះ ឬបើកូនពិការរបស់អ្នកបានរើ

ទៅទទួលការព្យាបាលនៅឯមន្ទីរថែទាំវេជ្ជសាស្ត្រ ។
"ត្រឡប់ទៅកាន់ឯកសារដើមវិញ"

[4] ឪពុកម្ដាយខ្លះ បានរាយការណ៍ថា ការិយាល័យបេឡាសន្តិសុខសង្គម ប្រចាំមូលដ្ឋានបានប្រាប់ពួកគេថា បេឡាសន្តិសុខសង្គម មិនអាចទទួលយក សំណៅឯកសារច្បាប់ថតចម្លងបានឡើយ ។ នេះមិនមែនជាព័ត៌មាន ដែលត្រឹមត្រូវឡើយ ។ នៅក្នុងលិខិតអំពីការផ្លាស់ប្ដូរប្រាក់ចំណូល អ្នកត្រូវស្បថ ក្រោមការពិន័យពីភាពភូតភរថា សំណៅថតចម្លងដែលអ្នកផ្ញើជូនយើងខ្ញុំ គឺជាសំណៅពិតដែលបានថតចេញពីសំណៅដើមទាំងស្រុង ។
"ត្រឡប់ទៅកាន់ឯកសារដើមវិញ"

[5] មានគ្រួសារខ្លះ បានរាយការណ៍ថា ការិយាល័យបេឡាសន្តិសុខសង្គម ប្រចាំមូលដ្ឋានរបស់ពួកគេ បានប្រាប់ថា ពួកគេមិនចាំបាច់ផ្ញើរបាយការណ៍អំពី ការផ្លាស់ប្ដូរប្រាក់ចំណូលប្រចាំខែឡើយ គឺគេនិយាយថា ការិយាល័យ បេឡាសន្តិសុខសង្គមនឹងធ្វើការកែសម្រួលនៅពេលធ្វើការពិនិត្យប្រាក់ចំណូល ប្រចាំឆ្នាំ ។ ជួនកាលព័ត៌មាននេះ គឺជាការពិត នៅពេលដែល បេឡាសន្តិសុខសង្គម រៀបចំដើម្បីធ្វើការកែសម្រួលចំពោះ អត្ថប្រយោជន៍របស់អ្នក ក្នុងករណីដែលយើងរំពឹងឃើញថា ប្រាក់ចំណូលរបស់អ្នក នឹងមានការឡើងចុះ ។ បើអ្នកទទួលបានប្រាក់ឈ្នួលប្រចាំសប្ដាហ៍ ជួនកាលអ្នក ទទួលបានសែកចំនួនប្រាំដង នៅក្នុងខែខ្លះ បើអ្នកទទួលបានប្រាក់ឈ្នួលរៀងរាល់ពីរសប្ដាហ៍ នៅពេលនោះ ក្នុងមួយឆ្នាំ មានពីរខែដែលអ្នកទទួលបានសែកចំនួនបីដង ។ នៅក្នុងពេលធ្វើការពិនិត្យប្រាក់ចំណូលរបស់អ្នកប្រចាំឆ្នាំ បេឡាសន្តិសុខសង្គម អាចរៀបជាកម្មវិធី ចំពោះការរំពឹងអំពីភាពឡើងចុះនៃប្រាក់ចំណូលរបស់អ្នក នៃ ឆ្នាំខាងមុខផងដែរ ។ ទោះជាយ៉ាងណាក៏ដោយ ប្រសិនបើបេឡាសន្តិសុខសង្គម មិនបានផ្ដល់ឲ្យអ្នកនូវអ្វីមួយជាលាយល័ក្ខណ៍អក្សរដែលនិយាយថា អ្នកមិនត្រូវ រាយការណ៍អំពីការផ្លាស់ប្ដូរប្រាក់ចំណូល អ្នកត្រូវតែផ្ញើឲ្យយើងខ្ញុំ នូវ របាយការណ៍អំពីការផ្លាស់ប្ដូរប្រាក់ចំណូល ។ បើអ្នកមិនរាយការណ៍ទេ ហើយមានការ ផ្ដល់ជំនួយឲ្យអ្នកលើសកំណត់ បេឡាសន្តិសុខសង្គម នឹងនៅតែនិយាយថា អ្នកមានកំហុស ពីព្រោះអ្នកមិនបានរាយការណ៍អំពីការផ្លាស់ប្ដូរប្រាក់ចំណូល របស់អ្នក ។ "ត្រឡប់ទៅកាន់ឯកសារដើមវិញ"

[6] ក្រម 42 សហរដ្ឋអាមេរិក វគ្គទី 1309 ក្រមបទបញ្ញត្តិរបស់រដ្ឋកាលីហ្វ័រនីញ៉ា (C.C.R., California Code of Regulations), Title 22 វគ្គទី 50555.1 ។ ចំពោះករណីគ្រួសារ លោក អ្នកស្រីប៉ោម ជាឧទាហរណ៍ ក នៅក្នុងទំព័រទី ៥ កូនពីរនាក់ផ្សេងទៀតរបស់គាត់ អាចមានលក្ខណៈសម្បត្តិទទួលបានជំនួយ Medi-Cal ដោយអាស្រ័យលើប្រាក់ចំណូលមានចំនួនស្មើសូន្យ ។ ឪពុកម្ដាយ អាចមិនមានលក្ខណៈសម្បត្តិទទួលបានជំនួយនេះឡើយ ដោយសារពួកគាត់ ទាំងពីរនាក់ សុទ្ធតែមានការងារធ្វើ ។ នៅក្នុងករណីគ្រួសារដែលមាន

ឪពុកម្តាយទោល (មានតែឪពុក ឬម្តាយ) ឬករណីដែលម្តាយ ឬឪពុកមិនមាន
ការងារធ្វើ ឬធ្វើការបានទទួលកម្រៃតិចតួច ឬជាជនពិការ
បូករួមទាំងពិការភាពក្នុងរយៈពេលខ្លី ពេលនោះឪពុក/ម្តាយ ក៏អាចមានសិទ្ធិ
ទទួលបានជំនួយពី Medi-Cal ដែរ ។ បើឪពុក ឬម្តាយ
កំពុងតែទទួលបានជំនួយសេវាកម្មជ្រោមជ្រែងដល់អ្នកជម្ងឺនៅតាមផ្ទះ ដើម្បីផ្តល់
ការថែទាំកូនជាជនពិការ ប្រាក់ចំណូលពីជំនួយនេះ មិនត្រូវរាប់បញ្ចូលឡើយ
នៅពេលយើងខ្ញុំធ្វើការកំណត់អំពីសិទ្ធិទទួលបាន
ជំនួយហិរញ្ញវត្ថុពីបេឡាសន្តិសុខសង្គម ហើយវាក៏មិនត្រូវរាប់បញ្ចូលដែរ
នៅពេលកំណត់អំពីភាពមានសិទ្ធិទទួលបានជំនួយ Medi-Cal នៃសមាជិក
ដទៃទៀតនៅក្នុងគ្រួសារនេះ ដោយសារ
តែសេវាកម្មជ្រោមជ្រែងដល់អ្នកជម្ងឺនៅតាមផ្ទះនៃសិទ្ធិជាជម្រើស
អាទិភាពរបស់សហគមន៍ ។ "ត្រឡប់ទៅកាន់ឯកសារដើមវិញ"

[7] បើអ្នកជាមនុស្សមានមុខរបរដោយខ្លួនឯង បេឡាសន្តិសុខសង្គម ចង់
ដឹងអំពីប្រាក់ចំណូលដុលរបស់អ្នកដែលបានកែសម្រួលរួចហើយ ។ ក្រម 20
នៃបញ្ញត្តិសហគមន៍ វគ្គទី 416.1110(b) ។
សូមយកមកកាន់បេឡាសន្តិសុខសង្គមនូវឯកសារប្រកាសពន្ធរបស់អ្នក
កាលពីឆ្នាំមុន ជាមួយនឹងព័ត៌មានស្តីអំពីឯកសារប្រាក់ចំណូលដុលរបស់អ្នកក្នុង
ឆ្នាំនេះផងដែរ ។ បេឡាសន្តិសុខសង្គម នឹងពិនិត្យមើលការប្រកាសពន្ធរបស់អ្នក
កាលពីឆ្នាំមុន ជាមួយនឹងឯកសារប្រាក់ចំណូលដុលរបស់អ្នកក្នុងឆ្នាំនេះ ។
បេឡាសន្តិសុខសង្គម នឹងពិនិត្យមើលឯកសារប្រកាសពន្ធរបស់អ្នកកាលពីឆ្នាំមុន
ដើម្បីយកមកធ្វើជាចំណុចវាស់វែង សម្រាប់
ការប៉ាន់ប្រមាណពីការកែសម្រួលប្រាក់ចំណូលដុលរបស់អ្នកក្នុងឆ្នាំនេះ ។
ប្រសិនបើប្រាក់ចំណូលដុលរបស់អ្នកកាលពីឆ្នាំមុនមានចំនួន $៤0,000
តែប្រាក់ចំណូលដុលរបស់អ្នកដែលបានកែសម្រួល
(អ្វីដែលអ្នកបានបង់ពន្ធក្រោយពេលកាត់កង ចំណាយលើការ
ប្រកបមុខរបរដែលជាសេវាកម្មប្រាក់ចំណូលផ្ទៃក្នុង) មានចំនួន $១៨,000 ឬ
៤៥% នៃប្រាក់ចំណូលដុលដែលអ្នកបានទទួល បេឡាសន្តិសុខសង្គម
នឹងប៉ាន់ប្រមាណថា ប្រាក់ចំណូលដុលរបស់អ្នកដែលបានកែសម្រួលក្នុងឆ្នាំនេះគឺ
៤៥% នៃប្រាក់ចំណូលសរុបដែលអ្នកត្រូវទទួលបានក្នុងឆ្នាំនេះ ។ ដោយសារ
ប្រាក់ចំណូលពីមុខរបរផ្ទាល់ខ្លួន ត្រូវបានកំណត់ជាលក្ខណៈប្រចាំឆ្នាំ
ដែលក្រោយមកត្រូវបានបែងចែកដោយចំណែកស្មើៗគ្នាចំនួន១២ខែ
ដោយអនុលោមទៅតាម ក្រម 20 នៃបទបញ្ញត្តិសហព័ន្ធ វគ្គទី 416.1111(b) អ្នក
នឹងត្រូវប្រើសត្យានុម័តិនៃការប៉ាន់ប្រមាណ ដើម្បីការកែសម្រួល នៅពេលអ្នក
ធ្វើការរៀបចំប្រកាសពន្ធរបស់អ្នក ។

បេឡាសន្តិសុខសង្គម មិនបានរាប់បញ្ចូលទ្រព្យធនដែលចាំបាច់សម្រាប់ការ
ជ្រោមជ្រែងខ្លួនឯង បូករួមទាំងការ
ជ្រោមជ្រែងខ្លួនឯងក្នុងនាមជានិយោជិកផងដែរ ។ ក្រម 42 សហរដ្ឋអាមេរិ វគ្គទី

1382b(a)(3) ។ ត្រង់នេះ គឺរួមបញ្ចូលនូវបញ្ជីសារពើភណ្ឌ កុំព្យូទ័រ ឧបករណ៍កសិដ្ឋាន និងបសុសត្វ ដីកសិដ្ឋាន គណនីធនាគារដាច់ដោយឡែក សម្រាប់មុខរបរ អគារ កាណូតនេសាទ ក៏ដូចជារថយន្ត ដែលអ្នកត្រូវការប្រើ ដើម្បីធ្វើការ ឬជាយានយន្តដែលចាំបាច់សម្រាប់ធ្វើដំណើរទៅធ្វើការ និងត្រឡប់មកវិញ ។ “ត្រឡប់ទៅកាន់ឯកសារដើមវិញ”

8 មាននិយោជកខ្លះ បានរៀបជាផែនការដែលអនុញ្ញាតិឲ្យអ្នក អាចដាក់ប្រាក់ទៅក្នុងគណនីពិសេស ដើម្បីទុកសម្រាប់បង់ថ្លៃថែទាំកូន ឬថ្លៃថែទាំសុខភាព ដោយអនុលោមទៅតាមវគ្គទី 125 នៃក្រមប្រាក់ចំណូលផ្ទៃក្នុង (Internal Revenue Code) ។ ទាំងនេះ ជាទូទៅត្រូវបានគេហៅថា “ផែនការសម្រាប់បង់ប្រាក់” (“cafeteria plans”) ។ ប្រាក់ដែលត្រូវបានទុកដាក់ក្នុងគណនីទាំងនេះ ហើយដែលត្រូវប្រើសម្រាប់អត្ថប្រយោជន៍ដែលត្រូវទទួលបាន មិនត្រូវបានគេចាត់ទុកថាជា “ប្រាក់ចំណូល” ឡើយ ដោយសារថា អ្នកមិនបានបង់ថ្លៃពន្ធបេឡាសន្តិសុខសង្គមចំពោះប្រាក់ចំណូលនេះឡើយ ។ ក្រម 20 នៃបទបញ្ញត្តសហព័ន្ធ វគ្គទី 416.1861 ។

ប្រាក់ចំណូលដុលពីការងាររបស់អ្នក សម្រាប់គោលបំណងចំណូលបេឡាសន្តិសុខបង្គ្រប់ គឺជាប្រាក់ចំណូលដុលរបស់អ្នក ដកប្រាក់ដែលអ្នកដាក់បញ្ចូលទៅក្នុងផែនការសម្រាប់បង់ប្រាក់ឡើយ ។ ទោះជាយ៉ាងណាក៏ដោយ ប្រាក់ចំណូលដែលត្រូវដាក់ទៅក្នុងគណនីចូលនិវត្តន៍សម្រាប់ពន្ធលើជម្រក *ត្រូវ*រាប់ជាប្រាក់ចំណូល ។ ថវិកានៅក្នុងគណនីចូលនិវត្តន៍ ឬគណនីសោធននិវត្តន៍របស់ឪពុកម្តាយ គឺជាធនធានដែលត្រូវបានលើកលែង *ដែលមិនបានចាត់*ជាប្រាក់ចំណូលចំពោះកុមារឡើយ ។ ក្រម 20 នៃបញ្ញត្តិសហគមន៍ វគ្គទី 416.1202(b) ។ “ត្រឡប់ទៅកាន់ឯកសារដើមវិញ”

9 ដោយសារតែគណនេយ្យប្រតិសកម្មប្រចាំខែ (សូមអានទំព័រទី 1-២) ការគណនាប្រាក់ចំណូល ដែលអ្នកបានទទួលក្នុងខែវិច្ឆិកា និងខែធ្នូ ត្រូវតែប្រើអត្រាអត្ថប្រយោជន៍សហព័ន្ធ សម្រាប់ឆ្នាំបន្ទាប់ ។ នេះក៏ដោយសារតែសែកប្រាក់ចំណូលសន្តិសុខសង្គម ដែលអ្នកបានទទួលក្នុងខែមករា និងខែកុម្ភៈ គឺត្រូវតែឆ្លុះបញ្ចាំងនឹងប្រាក់ចំណូលដែលអ្នកបានទទួល ហើយត្រូវចាត់ចូលជាប្រាក់ចំណូលសម្រាប់កុមារក្នុងខែវិច្ឆិកា និងខែធ្នូកាលពីឆ្នាំមុន ។ “ត្រឡប់ទៅកាន់ឯកសារដើមវិញ”

10 ប្រាក់ចំណូលអតិបរមាប្រចាំឆ្នាំ និងប្រចាំខែ មានការកើនឡើងក្នុងឆ្នាំនីមួយៗ ដោយសារអ្នកទទួលបានប្រាក់ឧបត្ថម្ភប្រចាំឆ្នាំសម្រាប់ការចំណាយក្នុងជីវិតប្រចាំថ្ងៃ ។ ក្រម 20 នៃបទបញ្ញត្តិសហព័ន្ធ វគ្គទី 416.112(c)(3)(B) ។ បទបញ្ញត្តនេះ ផ្តល់ជូននូវភាពបត់បែន និងការសម្រួល ចំពោះពិការភាព

នៅពេលយើងធ្វើការកំណត់ចំពោះពេលដែលកុមារ ឬមនុស្សជំទង់គឺជាសិស្ស សម្រាប់គោលបំណងការកាត់កងប្រាក់ចំណូលពីការងារ ។ ក្រម 20 នៃបទបញ្ញត្តសហព័ន្ធ វគ្គទី 416.1861 ។

បទបញ្ញត្តិ និងលក្ខន្តិកៈនេះ មានដាក់ឲ្យអាននៅឯបណ្ណាល័យសាធារណៈ ។ ឯកសារទាំងនេះ ក៏មាននៅឯវិបសៃត៍របស់បេឡាសន្តិសុខសង្គមផងដែរ តាមអាសយដ្ឋាន ៖ www.ssa.gov ។ នៅពេលអ្នកចូលទៅក្នុងវិបសៃត៍របស់បេឡាសន្តិសុខសង្គម សូមចុចលើពាក្យ “បទបញ្ញត្តិកម្មវិធីរបស់យើង” (our program rules) ដែលមានទីតាំងនៅផ្នែកខាងស្តាំនៃវិបសៃត៍នេះ ។

“ត្រឡប់ទៅកាន់ឯកសារដើមវិញ”

*Disability Rights California បានទទួលមូលនិធិឧបត្ថម្ភពីប្រភពផ្តល់ជំនួយនានាមួយចំនួន ។ សម្រាប់បញ្ជីលម្អិតនៃអ្នកផ្តល់ជំនួយ សូមទស្សនាគេហទំព័រ* http://www.disabilityrightsca.org/Documents/ListofGrantsAndContracts.html ។